## <u>ឱកាសស្មើគ្នាគឺជាច្បាប់</u>

ការរើសអើងដោយសារចំណុចខាងក្រោមនេះ គឺជាអំពើខុសច្បាប់ សម្រាប់បណ្ដាញច្នៃបង្កើតថ្មី របស់កម្លាំងពលកម្មច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) និង អ្នកចុះកិច្ចសន្យាណាមួយរបស់ផ្នែកនេះ, ក្នុងនាមជាអ្នកទទួលផល ពីជំនួយហិរញ្ញវត្ថុសហព័ន្ធ:

1. ប្រឆាំងនឹងបុគ្គលណាម្នាក់ នៅក្នុងសហរដ្ឋអាមេរិក ដោយសារ ជាតិសាសន៍; ពណ៌សម្បុរ; សាសនា; ភេទ (រួមទាំង ការមានគភ៌, កំណើតកូន, និង បញ្ហាផ្នែកវេជ្ជសាស្ត្រ ដែលពាក់ព័ន្ធ, ការបែងចែងភេទ, ស្ថានភាពប្ដូរភេទ, និង អត្តសញ្ញាណភេទ); ជាតិពីកំណើត (រួមទាំងសមត្ថភាពផ្នែកភាសាអង់គ្លេស ដែលមានកម្រិត); អាយុ; ពិការភាព, ឬ សម្ព័ន្ធ ផ្នែកនយោបាយ ឬ ជំនឿ។
2. ប្រឆាំងនឹងអ្នកទទួលផល, អ្នកដាក់ពាក្យស្នើសុំ, ឬអ្នកចូលរួម របស់កម្មវិធីនានា ដែលទទួលបានជំនួយហិរញ្ញវត្ថុ ក្រោមឋានៈទី I (Title I) នៃច្បាប់ ស្ដីពីឱកាស និងការច្នៃបង្កើតថ្មី របស់កម្លាំងពលកម្ម (WIOA) ឬ ដែលគ្រប់គ្រងដោយ ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ដោយសារឋានៈសញ្ជាតិឬ ការចូលរួមរបស់បុគ្គលម្នាក់ៗ ក្នុងសកម្មភាពឬ កម្មវិធីជំនួយហិរញ្ញវត្ថុ របស់ WIOA ឋានៈទី I (Title I) ឬ របស់ ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ។

ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) និងអ្នកចុះកិច្ចសន្យាបន្ត របស់ផ្នែកនេះមិនត្រូវរើសអើងចំពោះកិច្ចការណាមួយ ដូចតទៅនេះ ៖

1. ការសម្រេចលើបុគ្គលដែលត្រូវបានឱ្យចូល ឬ មានលទ្ធភាពទទួលបាន, ចំពោះ WIOA ឋានៈទី I (Title I) ណាមួយ ឬសកម្មភាព ឬ កម្មវិធីជំនួយហិរញ្ញវត្ថុ របស់ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ។
2. ការផ្ដល់ឱកាស នៅក្នុង, ឬ ការប្រព្រឹត្តចំពោះបុគ្គលណាម្នាក់ ពាក់ព័ន្ធនឹង កម្មវិធី ឬ សកម្មភាព មួយ។
3. ការធ្វើការសម្រេចចិត្តផ្នែកការងារ នៅក្នុងការគ្រប់គ្រង ឬ ដែលពាក់ព័ន្ធនឹងកម្មវិធី ឬសកម្មភាពមួយ។

## <u>រឿងដែលត្រូវធ្វើ ប្រសិនបើលោកអ្នកគិតថា លោកអ្នកបានពើបប្រទះនឹង ការរើសអើង</u>

ប្រសិនបើលោកអ្នកបានប្រឈមនឹងការរើសអើងក្រោម WIOA ឋានៈទី I (Title I) ឬ កម្មវិធី ឬ សកម្មភាព ដែលទទួលបានជំនួយហិរញ្ញវត្ថុពី ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway), លោកអ្នក ឬ អ្នកតំណាងឱ្យលោកអ្នកអាចដាក់ ពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរក្នុងរយៈពេល <u>**180 ថ្ងៃ**</u> គិតចាប់ពីកាលបរិច្ឆេទកើតមានការរំលោភបំពាន ដែលរងការចោទប្រកាន់ ដោយផ្ញើរជាលិខិត ឬ ជាសារអេឡិចត្រូនិក ទៅ<u>*បុគ្គលណាម្នាក់*</u> ខាងក្រោមនេះ ៖

1. អាលីហ្សា មុនណូ (Alisa Munoz), មន្ត្រីផ្នែកឱកាសស្មើគ្នាន របស់ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway)
   3447 វុក្ខវិថីអាត្លង់ទិក (Atlantic Avenue), ទីក្រុងឡុងប៊ិច, ទីក្រុងកាលីហ្វ័រញ៉ា CA 90807
   562.570.3748, TTY 562.570.4629
   Alisa.Munoz@pacific-gateway.org

2. ប្រធានមជ្ឈមណ្ឌលសិទ្ធិជនស៊ីវិល (CRC)
   ក្រសួងការងារ ស.រ.អ
   200 វុក្ខវិថីរដ្ឋធម្មនុញ្ញ (Constitution Avenue NW), បន្ទប់ N-4123, វ៉ាស៊ីនតោន, DC 20210
   www.dol.gov/crc

ពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដោយបំពេញ ទម្រង់បែបបទពាក្យបណ្ដឹង ចំពោះការរើសអើង របស់ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ហើយត្រូវមាន ព័ត៌មាន ដូចតទៅនេះ៖

1. ឈ្មោះពេញនិងអាសយដ្ឋានរបស់
2. ឈ្មោះពេញនិងអាសយដ្ឋានរបស់ភាគីដែលរងការចោទប្រកាន់។
3. សេចក្ដីថ្លែងច្បាស់លាស់អំពីអង្គហេតុ ពាក់ព័ន្ធនឹងការចោទប្រកាន់។
4. ហត្ថលេខារបស់លោកអ្នកឬហត្ថលេខារបស់អ្នកតំណាងពេញសិទ្ធិ របស់លោកអ្នក។

ប្រសិនបើលោកអ្នកដាក់ពាក្យបណ្ដឹងរបស់លោកអ្នកដោយផ្ទាល់ ទៅ ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway), លោកអ្នកត្រូវរង់ចាំ រហូតដល់ពេលដែល ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ចេញ សេចក្ដីជូនដំណឹង ជាលាយល័ក្ខណ៍អក្សរ ស្ដីពីវិធានការស្ដាពរ ឬ រហូតដល់រយៈពេល 90 ថ្ងៃ បានកន្លងទៅ (កំឡុងពេលណាមួយ ដែលលឿនជាងគេ),មុនពេលដាក់ពាក្យបណ្ដឹងទៅមជ្ឈមណ្ឌលសិទ្ធិស៊ីវិល (CRC)។

ប្រសិនបើច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) មិនចេញសេចក្ដីជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ស្ដីពីវិធានការស្ដាពរ ក្នុងរយៈពេល <u>**90 ថ្ងៃ**</u> គិតចាប់ពីថ្ងៃ ដែលលោកអ្នកបានដាក់ ពាក្យបណ្ដឹង របស់លោកអ្នក, លោកអ្នកអាចដាក់ ពាក្យបណ្ដឹង ទៅមជ្ឈមណ្ឌលសិទ្ធិស៊ីវិល (CRC) មុនពេលលោកអ្នកទទួលបានសេចក្ដីជូនដំណឹងនោះ។ ទោះជាយ៉ាងនេះក្ដី, លោកអ្នកត្រូវដាក់ពាក្យបណ្ដឹង របស់លោកអ្នក ទៅមជ្ឈមណ្ឌលសិទ្ធិស៊ីវិល (CRC) ក្នុងរយៈពេល 30 ថ្ងៃគិតចាប់ពីកាលបរិច្ឆេទកំណត់ នៃថេរវេលា 90 ថ្ងៃ (និយាយម្យ៉ាងទៀត, ក្នុងរយៈពេល 120 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទ ដែលបានដាក់ពាក្យបណ្ដឹងទៅច្រកផ្លូវប៉ាស៊ីហ្វិក [Pacific Gateway] តាំងពីដំបូងនោះ)។

ប្រសិនបើច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ផ្ដល់ សេចក្ដីជូនដំណឹង ជាលាយល័ក្ខណ៍អក្សរ ស្ដីពីវិធានការស្ដាពរ ចំពោះពាក្យបណ្ដឹង របស់លោកអ្នក, ប៉ុន្តែ លោកអ្នកមិនពេញចិត្ត នឹងសេចក្ដីសម្រេច ឬ ដំណោះស្រាយនោះ, លោកអ្នកអាចដាក់ ពាក្យបណ្ដឹងទៅ CRC បាន។ លោកអ្នកត្រូវដាក់ពាក្យបណ្ដឹងទៅមជ្ឈមណ្ឌលសិទ្ធិស៊ីវិល (CRC) ក្នុងរយៈពេល <u>**30 ថ្ងៃ**</u> គិតពីកាលបរិច្ឆេទ ដែលលោកអ្នកទទួលបាន សេចក្ដីជូនដំណឹងស្ដីពីវិធានការស្ដាពរ។

WIOA ឋានៈទី I (Title I) - កម្មវិធីឬសកម្មភាព ដែលទទួលបានជំនួយហិរញ្ញវត្ថុគឺជាកម្មវិធី/និយោជកឱកាសស្មើគ្នា។ សេវានិងជំនួយសង្គ្រោះមានផ្ដល់ជូនតាមសំណើចំពោះជនពិការ។ ដើម្បីស្នើសុំឱ្យមានការសម្របសម្រួល សមហេតុផល, សូមទូរសព្ទទៅ 562.570.4711 ឬ TTY 562.570.4629 យ៉ាងហោចណាស់ ឱ្យបាន 72 ម៉ោង មុនពេលមានព្រឹត្តិការណ៍។

**រឿងត្រូវធ្វើប្រសិនបើលោកអ្នកគិតថាបណ្ដាញច្នៃបង្កើតថ្មី របស់កម្លាំងពលកម្មច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway), អ្នកផ្ដល់សេវាណាមួយ, ឬ បុគ្គលិកណាម្នាក់ របស់ផ្នែកនេះ បានរំលោភបំពាន លើបញ្ញត្តិណាមួយ នៃ ច្បាប់ ស្ដីពីឱកាស និងការច្នៃបង្កើតថ្មី របស់កម្លាំងពលកម្ម (WIOA); បទបញ្ញត្តិ, គោលនយោបាយ និងសេចក្ដីណែនាំនានា នៅ កម្រិតរដ្ឋ/កម្រិតមូលដ្ឋាន របស់ WIOA ។**

លោកអ្នកអាចដាក់បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង ក្នុងរយៈពេល **មួយឆ្នាំ** គិតចាប់ពីកាលបរិច្ឆេទ មានការរំលោភបំពាន ដែលរងការចោទប្រកាន់ ។

បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង របស់លោកអ្នក ត្រូវធ្វើឡើង ជាលាយល័ក្ខណ៍អក្សរ, មានចុះហត្ថលេខា, មានដាក់កាលបរិច្ឆេទ និង រួមមានព័ត៌មាន ដូចខាងក្រោមនេះ ៖

1. ឈ្មោះពេញ, លេខទូរសព្ទ និង អាសយដ្ឋាន របស់លោកអ្នក ។
2. ឈ្មោះពេញ, លេខទូរសព្ទ និង អាសយដ្ឋាន របស់ភាគីចុងចោទ នៃ បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង ដែលបានដាក់ ។
3. សេចក្ដីថ្លែង ច្បាស់លាស់ និងជាក់លាក់ អំពីអង្គហេតុ និង កាលបរិច្ឆេទនានា ដែលរៀបរាប់ អំពីការរំលោភបំពាន ដែលរងការចោទប្រកាន់ ។
4. បញ្ញត្តិនានា របស់ WIOA, បទបញ្ញត្តិនានា របស់ WIOA និង/ឬ សេចក្ដីណែនាំនានា នៅ កម្រិតរដ្ឋ/កម្រិតមូលដ្ឋាន របស់ WIOA ត្រូវបានគិតថា រងការរំលោភបំពាន ។
5. បណ្ដឹងសារទុក្ខឬពាក្យបណ្ដឹងប្រឆាំងនឹងបុគ្គលដូចជាបុគ្គលិកឬ អ្នកចូលរួម, ត្រូវបង្ហាញពីរបៀបដែលបុគ្គលនោះមិនគោរពតាមច្បាប់, បទបញ្ញត្តិ, ឬ សេចក្ដីណែនាំ របស់ WIOA។
6. ការប៉ះប៉ូវ ត្រូវបានស្វែងរក។

ប្រសិនបើលោកអ្នកស្នើសុំជំនួយបច្ចេកទេស, ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) និងអ្នកផ្ដល់សេវា របស់ផ្នែកនេះ ត្រូវផ្ដល់ជំនួយ ដល់លោកអ្នក ក្នុងការដាក់ បណ្ដឹងសារទុក្ខ ឬពាក្យបណ្ដឹង ។

បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង របស់លោកអ្នក ត្រូវផ្ញើរជូនទៅ ឬ ផ្ញើរជា សារអេឡិចត្រូនិក ទៅ ៖

**អាលីហ្សា មុនណូ (Alisa Munoz), មន្ត្រី EO របស់ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway)**
**3447 វិថី អាត្លង់ទិក (Atlantic Avenue)**
**ទីក្រុងឡុងប៊ិច, ទីក្រុងកាលីហ្វ័រញ៉ា CA 90807**
**Alisa.Munoz@pacific-gateway.org**

កាលបរិច្ឆេទដាក់បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹងជាផ្លូវការគឺ កាលបរិច្ឆេទដែលច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ឬ អ្នកផ្ដល់សេវារបស់ផ្នែកនេះទទួលបាន។

មន្ត្រី EO របស់ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ឬ អ្នកតំណាង ដែលបានចាត់តាំងរួច ត្រូវទទួលបានឱកាស ដើម្បីដោះស្រាយ បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង តាមរយៈដំណើរការ មិនផ្លូវការ មុនពេលបើកសវនាការ ។

ប្រសិនបើបណ្ដឹងសារទុក្ខឬពាក្យបណ្ដឹងមិនត្រូវបានដោះស្រាយ តាមរយៈ ដំណើរការដោះស្រាយ មិនផ្លូវការទេ, នោះសវនាការ គួរត្រូវប្រារព្ធឡើង ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីពេលដាក់ បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង ។

ប្រសិនបើលោកអ្នកមិនទទួលបានសេចក្ដីជូនដំណឹង អំពីសេចក្ដីសម្រេចចំពោះពាក្យបណ្ដឹងរបស់លោកអ្នក ពីច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) ក្នុងរយៈពេល **60 ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទ ដែលលោកអ្នកបានដាក់ បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង ឬ មានឧបទ្ទវហេតុ នៃការដាក់កំហិត, ការបង្ខិតបង្ខំ ឬ ការផ្ដាច់ផ្ដាញ់តប ដោយសារការដាក់ បណ្ដឹងសារទុក្ខ ឬ ពាក្យបណ្ដឹង ដែលលោកអ្នកអាចដាក់សំណើសុំ ឱ្យមានការពិនិត្យឡើងវិញ របស់ EDD ក្នុងរយៈពេល **15 ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទ ដែលលោកអ្នកគួរទទួលបាន សេចក្ដីសម្រេច ឬ កាលបរិច្ឆេទ ដែលមាន ការដាក់កំហិត, ការបង្ខិតបង្ខំ, ការផ្ដាញ់តប កើតឡើង ។

ប្រសិនបើលោកអ្នកទទួលបានសេចក្ដីជូនដំណឹង អំពីសេចក្ដីសម្រេច ចំពោះពាក្យបណ្ដឹង របស់លោកអ្នក ពីច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway), ប៉ុន្តែ លោកអ្នកមិនពេញចិត្ត ចំពោះសេចក្ដីសម្រេចនោះ, លោកអ្នកអាចដាក់ បណ្ដឹងឧទ្ធរណ៍ ក្នុងរយៈពេល **10 ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទ ដែលលោកអ្នកបានទទួល សេចក្ដីជូនដំណឹង អំពីសេចក្ដីសម្រេចនោះ។

សំណើររបស់លោកអ្នកសុំឱ្យមានការពិនិត្យឡើងវិញរបស់ EDD ឬ បណ្ដឹងឧទ្ធរណ៍ត្រូវរួមមានព័ត៌មានដូចខាងក្រោមនេះ៖

1. ឈ្មោះពេញ, លេខទូរសព្ទ និង អាសយដ្ឋាន របស់លោកអ្នក ។
2. ឈ្មោះពេញ, លេខទូរសព្ទនិងអាសយដ្ឋានរបស់ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway)។
3. សេចក្ដីថ្លែងអំពីមូលដ្ឋានរបស់សំណើឬបណ្ដឹងឧទ្ធរណ៍។
4. ច្បាប់ចម្លងនៃឯកសារពាក់ព័ន្ធ ដូចជាបណ្ដឹងសារទុក្ខឬ ពាក្យបណ្ដឹង ដែលបានដាក់រួចនិងសេចក្ដីសម្រេច នៅមូលដ្ឋាន ប្រសិនបើមាន។

សំណើលោកអ្នកសុំឱ្យមាន ការពិនិត្យឡើងវិញ របស់ EDD ឬ បណ្ដឹងឧទ្ធរណ៍ ត្រូវផ្ញើរជូនទៅ៖

**ក្រសួងអភិវឌ្ឍន៍ការងារ - ផ្នែកពិនិត្យឡើងវិញលើអនុលោមភាព**
**800 អាគារលក់ទំនិញខាភីថល (Capitol Mall), MIC 22, ប្រអប់សំបុត្រ លេខ 826880**
**សាក្រាមែនតូ (Sacramento), ទីក្រុងកាលីហ្វ័រញ៉ា CA 94280-0001**

**ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានទទួល ឯកសារចម្លង នៃឯកសារនីតិវិធីដាក់ពាក្យបណ្ដឹងសង្ខេប សម្រាប់អតិថិជន របស់ច្រកផ្លូវប៉ាស៊ីហ្វិក (Pacific Gateway) សម្រាប់ពាក្យបណ្ដឹង ចំពោះការរើសអើង និងសម្រាប់ ពាក្យបណ្ដឹង និងបណ្ដឹងសារទុក្ខ ចំពោះកម្មវិធី រួចហើយ ។**

| ______________________ | ______________________ | ______________________ |
|---|---|---|
| ឈ្មោះរបស់អតិថិជន | ហត្ថលេខារបស់អតិថិជន ឬ ហត្ថលេខា របស់ឪពុកម្ដាយ/អាណាព្យាបាល (ប្រសិនបើអតិថិជន មានអាយុក្រោម 18 ឆ្នាំ) | កាលបរិច្ឆេទ |